**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០៨៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពី

## កាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធដែលត្រូវចំថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ឬថ្ងៃឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ

៚•៛

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីពង្រឹងការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងមានតម្លាភាព ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ កាលបរិច្ឆេទចុងក្រោយកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធដូចមានចែងក្នុងច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ ដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ (ថ្ងៃសៅរ៍ ឬ អាទិត្យ) ឬថ្ងៃឈប់សំរាកស្របតាមប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធនោះត្រូវលើកទៅថ្ងៃបន្ទាប់ដែលជាថ្ងៃធ្វើការ ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការកំណត់កាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធនេះ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700